# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
**លេខ** ១៨១ **គ.ជ.ប/អគ្គ/ប្រ.ភ.៣**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៧

## សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ១០:០០នាទីព្រឹក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីនីតិវិធីចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ និងការបញ្ជូនទិន្នន័យមក គ.ជ.ប នៅសាលសន្និសីទ គ.ជ.ប ក្រោមអធិបតីភាពឯកឧត្តម **គួយ ប៊ុនរឿន** អនុប្រធាន គ.ជ.ប ។

ភាគីពាក់ព័ន្ធដែលចូលរួមកិច្ចប្រជុំនេះរួមមាន ៖ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាលចំនួន ០៤ តំណាងគណបក្សនយោបាយចំនួន ០៦ ជំនាញការអង្គការ JICA ជំនាញការ EU ជំនាញការ IFES ជំនាញការ KOICA និងអង្គភាពសារព័ត៌មានចំនួន ១៦ សរុបចំនួន ៦០នាក់។

ឯកឧត្តម **គួយ ប៊ុនរឿន** មានប្រសាសន៍ថា កិច្ចប្រជុំនេះមានគោលបំណង ដើម្បីធ្វើការផ្សព្វផ្សាយអំពីគោលដៅ និងការអនុវត្តការងារធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧។ ឯកឧត្តមបន្តថា គោលដៅ នៃការធ្វើបច្ចុប្បន្នភាពបោះឆ្នោតនិងចុះការឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ គឺដើម្បីធានាឱ្យបាននូវបញ្ជីបោះឆ្នោតដែលមានភាពពេញលេញ ភាពត្រឹមត្រូវ និងមានបច្ចុប្បន្នភាពប្រកបដោយសុវត្ថិភាពតាមរយៈ ៖

- ការស្រង់ និងលុបឈ្មោះអ្នកបោះឆ្នោត ៖
  - ដែលបានទទួលមរណភាព
  - ដែលត្រូវបានដកហូតសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន
  - ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង

  ការសម្រេចលុបឈ្មោះអ្នកបោះឆ្នោត ត្រូវធ្វើឡើងដោយមានឯកសារជាសំអាងត្រឹមត្រូវ ច្បាស់លាស់ មានការបិទផ្សាយជាសាធារណៈឱ្យប្តឹងតវ៉ា ឬជំទាស់ និងមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់ពី គ.ជ.ប មុននឹងលុបឈ្មោះជននោះចេញពីបញ្ជីបោះឆ្នោត។
- ការកែតម្រូវឈ្មោះ ឬទិន្នន័យអ្នកបោះឆ្នោត តាមសំណើរបស់សាមីខ្លួនដោយផ្អែកលើឯកសារ សំអាងត្រឹមត្រូវ។
- ការចុះឈ្មោះបោះឆ្នោត សំដៅលើ ៖
  - ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត ហើយមិនទាន់បានចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦
  - ប្រជាពលរដ្ឋខ្មែរដែលទើបគ្រប់អាយុ ១៨ឆ្នាំ គិតត្រឹមថ្ងៃបោះឆ្នោត ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨
  - ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មីត្រូវទៅចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។

ចុងបញ្ចប់នៃកិច្ចប្រជុំឯកឧត្តម **គួយ ប៊ុនរឿន** បានអំពាវនាវដល់គណបក្សនយោបាយ សមាគម និង អង្គការមិនមែនរដ្ឋាភិបាល អង្គភាពសារព័ត៌មាន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចូលរួមសហការជាមួយ គ.ជ.ប ដើម្បីឱ្យដំណើរការនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ប្រព្រឹត្តទៅដោយរលូន និងធានាបាននូវសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរគ្រប់ៗគ្នា ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨៕

ប្រសាសន៍ដើមទាំងស្រុងរបស់ឯកឧត្តម **គួយ ប៊ុនរឿន** អនុប្រធាន គ.ជ.ប មានបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប www.necelect.org.kh៕